ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៩៧៤ ព.ណ.ភ.សណ

ភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦

## ជម្រាបមក

## លោក/លោកស្រីប្រធានក្រុមហ៊ុន តាំង សេង ហួត អ៊ិនធើណេសិនណល

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលភេសជ្ជៈប៉ូវកម្លាំងម៉ាក Carabao ក្នុង ព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **តាំង សេង ហួត អ៊ិនធើណេសិនណល**។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **តាំង សេង ហួត អ៊ិនធើណេសិនណល** ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Carabao Tawandang Co., Ltd. ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៩៣៨៤/04 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលភេសជ្ជៈប៉ូវកម្លាំងពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **តាំង សេង ហួត អ៊ិនធើណេសិនណល** ដែលទទួលបានពីក្រុមហ៊ុន Carabao Tawandang Co., Ltd. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតកត់ត្រានេះ មានសុពលភាពត្រឹមថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៨ ដោយគិតចាប់ពីក្រោយថ្ងៃចុះហត្ថលេខាចំនួន ៩០(កៅសិប) ថ្ងៃ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Carabao Tawandang Co., Ltd. ដែលជាម្ចាស់ម៉ាក ។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្ត ជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

អ៊ុក ប្រាជ្ញា

**ចម្លងជូន:**
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*